IOM UN MIGRATION

PROMISE
POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC



# គន្លឹះសម្រាប់ពលករទេសន្តរប្រវេសន៍ ដែលការងាររបស់ពួកគេរងផលប៉ះពាល់ពីការរាតត្បាតជាសកលនៃជំងឺកូវីដ១៩

## តើអ្នកបារម្ភអំពីជំងឺកូវីដ១៩ មែនទេ?

**គន្លឹះសាមញ្ញៗដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង**

- ជៀសវាងប៉ះពាល់អ្នកដែលមានរោគសញ្ញាទាំងនេះ៖ ក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហក់ ឬ គ្រុនក្តៅលើស ៣៧,៥ អង្សារសេ ។
- ជៀសវាងប៉ះពាល់ភ្នែក ច្រមុះ និងមាត់របស់អ្នក។
- លាងសម្អាតដៃរបស់អ្នកឱ្យបានញឹកញាប់ ជាមួយសាប៊ូរយៈពេល២០វិនាទី ឬសំអាតដៃរបស់អ្នក  ជាមួយទឹកអាល់កុលលាងដៃ ដែលមានបរិមាណជាតិអាល់កុលយ៉ាងហោចណាស់ ៧០%។
- ប្រសិនបើអ្នក ឬ នរណាម្នាក់ដែលនៅជុំវិញអ្នកកំពុងមានរោគសញ្ញាផ្លូវដង្ហើមមួយឬច្រើនដូចមាន រៀបរាប់ខាងលើ សូមពាក់ម៉ាស់។ សូមព្យាយាមកុំចាកចេញពីផ្ទះនិងសូមស្វែងរកដំបូន្មាន ពីអ្នកជំនាញផ្នែកសុខភាព។

សូមផ្តល់ព័ត៌មានទៅអ្នកដទៃ ដើម្បីឱ្យពួកគេអាចទទួលបានព័ត៌មានអំពីស្ថានភាព និង សូមកុំផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។ សម្រាប់បច្ចុប្បន្នភាពផ្លូវការអំពីជំងឺកូវីដ១៩ អ្នកអាចចូលមើលគេហទំព័រក្រសួងសុខាភិបាលថៃតាមរយៈ https://ddc.moph.go.th ជាភាសាថៃ និង ភាសាអង់គ្លេស គេហទំព័រក្រសួងសុខាភិបាលភូមា តាមរយៈ www.mohs.gov.mm ក្រសួងសុខាភិបាលកម្ពុជា តាមរយៈ www.cdcmoh.gov.kh ក្រសួងសុខាភិបាលឡាវ តាមរយៈ www.covid19.gov.la ។

## តើអ្នកកំពុងពិចារណាត្រឡប់ទៅផ្ទះវិញដែរឬទេ?

**តើអ្នកដឹងទេថាការធ្វើ ដំណើរនៅពេលនេះ មានហានិភ័យច្រើន?**

- ជាធម្មតា ការធ្វើដំណើរឆ្លងដែន ត្រូវឆ្លងកាត់កន្លែងដែលមានមនុស្សអ៊ូអរ និង អាចនាំឱ្យមានការចម្លងជំងឺកូវីដ១៩ តាមរយៈការក្អក កណ្តាស់ និង ការប៉ះពាល់ លើ វត្ថុនានា ដែលមានមេរោគ។
- ប្រសិនបើមាននរណាម្នាក់មានជំងឺ ជំងឺកូវីដ១៩ អាចចម្លងទៅទីកន្លែងសាធារណៈ រួមទាំងកន្លែងការងាររបស់អ្នកផងដែរ។
- ដោយសារជំងឺកូវីដ១៩ គេអាចបិទចំណុចត្រួតពិនិត្យអន្តោប្រវេសន៍ ដែលអាចនាំឱ្យប៉ះពាល់ដល់ការចូលមកវិញ និងការងាររបស់អ្នកនៅក្នុងប្រទេសថៃ។
- ជើងហោះហើរ និង ការឆ្លងកាត់ព្រំដែនមួយចំនួន អាចបិទក្រោមការជូនដំណឹងភ្លាមៗ ឬ បន្តបិទរយៈពេលវែង។ ប្រតិបត្តិការ និង វិធានការត្រួតពិនិត្យព្រំដែន អាចមានភាពខុសគ្នានៅតាម ទីតាំងផ្សេងៗគ្នា។ សម្រាប់ការណែនាំ និង ការផ្តល់ព័ត៌មានដែលមានបច្ចុប្បន្នភាព សូមទាក់ទងស្ថានទូត ឬ ស្ថានកុងស៊ុលរបស់អ្នក។
- សម្រាប់ពលករទេសន្តរប្រវេសន៍ដែលចូលមកប្រទេសថៃវិញក្រោយពេលចាកចេញ មានការកំណត់តម្លៃជាផ្លូវការចំនួន ១.០០០បាត សម្រាប់ការចូលមកវិញក្នុងមួយលើក និង ៣.៨០០បាត សម្រាប់ការអនុញ្ញាតឱ្យចូលមកវិញច្រើនលើក។

**គន្លឹះ:** នៅខណៈពេលដែលមិនទាន់មានភាពប្រាកដប្រជាបែបនេះ គេណែនាំឱ្យធ្វើដំណើរចំពោះតែករណីចាំបាច់ប៉ុណ្ណោះ និង ពិចារណាឡើងវិញទៅលើផែនការធ្វើដំណើរកំសាន្តរបស់អ្នក រហូតដល់ស្ថានភាពមានភាពប្រសើរឡើង ដើម្បីការពារខ្លួនអ្នក និង មនុស្សជុំវិញខ្លួនអ្នក។ ប្រសិនបើអ្នកត្រូវធ្វើដំណើរត្រឡប់ទៅផ្ទះវិញដោយសារមូលហេតុណាមួយ សូមទាក់ទងស្ថានទូត ឬ ស្ថានកុងស៊ុលរបស់អ្នក សម្រាប់ព័ត៌មាន និង ជំនួយផ្សេងៗ។

# តើអ្នកជាពលករទេសន្តរប្រវេសន៍ដែលការងាររបស់អ្នករងផលប៉ះពាល់ ពីការរាតត្បាតជាសកលនៃជំងឺកូវីដ១៩មែនទេ?

## តើអ្នកមានការការពារ តាមរយៈបេឡាររបបសន្តិសុខសង្គម ដែរឬទេ?

និយោជិតដែលបានផ្តល់វិភាគទានដល់បេឡាររបបសន្តិសុខសង្គម លើសពី៦ខែ ក្នុងរយៈពេល ១៥ខែចុងក្រោយ និងដែលបានបាត់បង់ការងារ រួមទាំងការបាត់បង់ការងារដោយសារប្រធានស័ក្តិ ដូចជា ការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ មានសិទ្ធិទទួលបានផែនការសំណងផ្សេងៗគ្នា (បច្ចុប្បន្នគិតត្រឹម ថ្ងៃ១៧ មេសា ២០២០)។ ផែនការសំណងលម្អិតមានសង្ខេបខាងក្រោម៖

- និយោជិត (រួមទាំងពលករទេសន្តរប្រវេសន៍) នៃធុរកិច្ចដែលត្រូវធ្វើចត្តាឡីស័កដោយសារការរាតត្បាតជំងឺជាសកល ឬដោយសារប្រធានស័ក្តិ មានសិទ្ធិទទួលបានបៀវត្សរ៍មូលដ្ឋានចំនួន ៦២% រហូតដល់ចំនួនទឹកប្រាក់ដែលមិនលើស ៩.៣០០បាត ក្នុងមួយខែ សម្រាប់រយៈពេល៩០ថ្ងៃ។
- និយោជិត (រួមទាំងពលករទេសន្តរប្រវេសន៍) នៃធុរកិច្ចដែលរាជរដ្ឋាភិបាលថៃបានផ្អាកដំណើរការ ដូចជារង្គសាល និងក្លឹបកំសាន្តមានសិទ្ធិ ទទួលបានបៀវត្សរ៍មូលដ្ឋានចំនួន ៦២% រហូតដល់ចំនួនទឹកប្រាក់ដែលមិនលើស ៩.៣០០បាត ក្នុងមួយខែ សម្រាប់រយៈពេល៩០ថ្ងៃ។
- និយោជិត (រួមទាំងពលករទេសន្តរប្រវេសន៍) ដែលត្រូវបានបញ្ឈប់ពីការងារ មានសិទ្ធិទទួលបានបៀវត្សរ៍មូលដ្ឋានចំនួន ៧០% រហូតដល់ចំនួនទឹកប្រាក់ដែលមិនលើស ១០.៥០០បាត ក្នុងមួយខែ សម្រាប់រយៈពេល២០០ថ្ងៃ។
- និយោជិត (រួមទាំងពលករទេសន្តរប្រវេសន៍) ដែលបានលាឈប់ពីការងារ មានសិទ្ធិទទួលបានបៀវត្សរ៍មូលដ្ឋានចំនួន ៤៥% រហូតដល់ចំនួនទឹកប្រាក់ដែលមិនលើស ៦.៧៥០បាត ក្នុងមួយខែ សម្រាប់រយៈពេល៩០ថ្ងៃ។
- ពលករ និង និយោជិត គប្បីចុះឈ្មោះតាមរយៈ https://www.sso.go.th

## តើអ្នកមានបញ្ហាផ្លូវច្បាប់ដែល អ្នកមិនអាចដោះស្រាយដោយសន្តិវិធីជាមួយនយោជករបស់ អ្នកដែរឬទេ?

អ្នកអាចដាក់ពាក្យបណ្តឹងតាមរយៈអធិការការងារ ឬ តុលាការការងារ នៅក្នុងតំបន់ដែលអ្នកធ្វើការ ឬតំបន់ដែលនយោជករបស់អ្នករស់នៅ ប្រសិនបើតុលាការអនុញ្ញាត។

សូមទូរស័ព្ទទៅបណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងការងារ តាមរយៈលេខ ១៥០៦ និង បន្ទាប់មកចុចលេខ២ ដើម្បីស្វែងរកជំនួយជាភាសាខ្មែរ ឡាវ និង ភូមា។

អ្នកអាចស្នើសុំឱ្យមន្ត្រីរដ្ឋាភិបាលឬសមាគមកម្មករនិយោជិតបញ្ជូនសំណុំរឿងទៅតុលាការជំនួសអ្នក ដោយមិនចាំបាច់ត្រូវបង់ប្រាក់ប្រដាប់ក្តី។

## តើអ្នកធ្វើការងារពេញម៉ោង ដែរឬទេ?

ប្រសិនបើអ្នកធ្វើការពេញម៉ោង អ្នកមានសិទ្ធិទទួលបានប្រាក់បំណាច់ការងារ នៅពេលដែលនយោជករបស់អ្នកបញ្ចប់កិច្ចសន្យា ក្រោយពេលដែលអ្នកបានបម្រើការងារយ៉ាងតិច ១២០ថ្ងៃ ជាបន្តបន្ទាប់ ជាមួយនិយោជកដដែល ដោយការទូទាត់ប្រាក់បំណាច់នេះមានលក្ខណៈដូចខាងក្រោម៖

- ១២០ថ្ងៃ ប៉ុន្តែតិចជាង១ឆ្នាំ៖ បៀវត្សរ៍ធម្មតា ស្មើនឹង៣០ថ្ងៃនៃថ្ងៃធ្វើការ
- ១-៣ឆ្នាំ៖ បៀវត្សរ៍ធម្មតា ស្មើនឹង៩០ថ្ងៃនៃថ្ងៃធ្វើការ
- ៣-៦ឆ្នាំ៖ បៀវត្សរ៍ធម្មតា ស្មើនឹង១៨០ថ្ងៃនៃថ្ងៃធ្វើការ
- ៦-១០ឆ្នាំ៖ បៀវត្សរ៍ធម្មតា ស្មើនឹង២៤០ថ្ងៃនៃថ្ងៃធ្វើការ
- ១០-២០ឆ្នាំ៖ បៀវត្សរ៍ធម្មតា ស្មើនឹង៣០០ថ្ងៃនៃថ្ងៃធ្វើការ
- លើសពី២០ឆ្នាំ៖ បៀវត្សរ៍ធម្មតា ស្មើនឹង៤០០ថ្ងៃនៃថ្ងៃធ្វើការ

ប្រសិនបើអ្នកមិនប្រាកដ ថាតើអ្នកមានសិទ្ធិទទួលបានប្រាក់បំណាច់ឬយ៉ាងណា អ្នកអាចទាក់ទងនាយកដ្ឋានកិច្ចការពារ និងសុខុមាលភាពការងារ តាមរយៈបណ្តាញទូរស័ព្ទទាន់ហេតុការណ៍លេខ ១៥០៦ របស់ក្រសួងការងារ។

ប្រសិនបើអ្នកមានបំណងចង់និយាយជាមួយការីទូរស័ព្ទជាភាសាខ្មែរ ឡាវ ឬ ភូមា សូមចុចលេខ២ នៅពេលដែលអ្នកចូលដល់មីនុយ។

## តើអ្នកជាពលករទេសន្តរប្រវេសន៍ដែលមានកាត ពណ៌ផ្កាឈូក ឬ ត្រូវបានជ្រើសរើសតាម រយៈអនុស្ស រណៈនៃការយោគយល់ រវាងប្រទេសថៃ និង ប្រទេសកំណើតរបស់អ្នក ដែរឬទេ?

ប្រសិនបើអ្នកជាពលករដែលត្រូវបានជ្រើសរើសតាមរយៈអនុស្សរណៈនៃការយោគយល់ ពីប្រទេសកម្ពុជា ឡាវ ភូមា ឬ វៀតណាម និង ប្រសិនបើនិយោជករបស់អ្នកក្ស័យធុន ឬ ត្រូវកាត់បន្ថយទំហំធុរកិច្ច ដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ អ្នកត្រូវបានអនុញ្ញាតឱ្យប្តូរនយោជក។ អ្នកក៏មានសិទ្ធិពន្យារការស្នាក់នៅ និង លិខិតអនុញ្ញាតការងាររបស់អ្នកផងដែរ (សូមមើលសេចក្តីលម្អិតខាងក្រោម)

## តើអ្នកត្រូវការប្តូរនិយោជក ដែរឬទេ?

- សុំការជូនដំណឹងជាផ្លូវការពីនិយោជករបស់អ្នក ដែលថ្លែងថាពួកគេបានបញ្ចប់កិច្ចសន្យាការងាររបស់អ្នក។
- និយោជកថ្មីរបស់អ្នកនឹងប្រើប្រាស់ឯកសារនេះ ដើម្បីចុះឈ្មោះអ្នកជាមួយការិយាល័យនៃនាយកដ្ឋានមុខរបរនិងការងារ។
- សូមបង្ហាញលិខិតឆ្លងដែន និង លិខិតអនុញ្ញាតការងារបច្ចុប្បន្នរបស់អ្នក ដើម្បីចុះឈ្មោះជាមួយ និយោជកថ្មី។

គន្លឹះ: សូមចងចាំថា អ្នកគួរមានឯកសារអត្តសញ្ញាណផ្ទាល់ខ្លួនទាំងអស់នេះ ជាប់ខ្លួនគ្រប់ពេល។

## តើអ្នកបារម្ភអំពីការផុតសុពលភាពនៃលិខិតអនុញ្ញាត សម្រាប់ការស្នាក់នៅ និងធ្វើការងាររបស់អ្នក មែនទេ?

ដោយសារតែការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ រាជរដ្ឋាភិបាលថៃ បានផ្តល់ការលើកលែងសម្រាប់ពលករទេសន្តរប្រវេសន៍ចំនួន៤ក្រុម (ក្រោមស្ថានភាពជាក់លាក់) ឱ្យបន្តធ្វើការងារ និង រស់នៅក្នុងប្រទេសថៃជាមួយអ្នកក្នុងបន្ទុករបស់ពួកគេដែលបានចុះឈ្មោះកន្លងមក រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។ ប្រសិនបើអ្នកស្ថិតនៅក្នុងក្រុមណាមួយក្នុងចំណោមក្រុមទាំង៤នេះ អ្នកត្រូវចុះឈ្មោះដើម្បីពន្យារលិខិតអនុញ្ញាតឱ្យធ្វើការងាររបស់អ្នក ឱ្យបានមុនថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០។ ក្រុមទី៥ ពោលគឺអ្នកក្នុងបន្ទុករបស់ពលករទេសន្តរប្រវេសន៍ ក៏អាចមានសិទ្ធិចុះឈ្មោះដើម្បីទទួលបានលិខិតអនុញ្ញាតឱ្យស្នាក់នៅ និង ធ្វើការងារផងដែរ។

ប្រសិនបើអ្នកបានចុះឈ្មោះរួចហើយ និយោជករបស់អ្នកនឹងមានបញ្ជីឈ្មោះមួយដែលចេញដោយនាយកដ្ឋានមុខរបរនិងការងារ។ អ្នកអាចបង្ហាញបញ្ជីឈ្មោះនេះទៅអាជ្ញាធរ រួមជាមួយនឹងលិខិតឆ្លងដែន និងលិខិតអនុញ្ញាតឱ្យធ្វើការងារបច្ចុប្បន្នរបស់អ្នក ដើម្បីធ្វើការងារនៅក្នុងប្រទេសថៃ ជាមួយនិយោជកដដែល រហូតដល់ដំណាច់ ខែមីនា ឆ្នាំ២០២២។ បើទោះជាដូច្នេះក្តី អ្នកត្រូវបំពេញដំណើរការពន្យារលិខិតអនុញ្ញាតឱ្យធ្វើការងាររបស់អ្នកឱ្យបានរួចរាល់ត្រឹម ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ហើយទិដ្ឋាការរបស់អ្នកត្រូវពន្យាររៀងរាល់ឆ្នាំ។ សូមពិនិត្យព័ត៌មានលម្អិតអំពីលក្ខខណ្ឌ និង ដំណើរការពន្យារខាងក្រោម៖

**ក្រុមពលករទេសន្តរប្រវេសន៍ និង អ្នកក្នុងបន្ទុករបស់ពួកគេ ដែលមានលក្ខខណ្ឌសមស្រប ក្នុងការចុះឈ្មោះដើម្បីទទួលបានលិខិតអនុញ្ញាតឱ្យស្នាក់នៅ និង ធ្វើការងារ៖**

- ក្រុម១៖ ពលករមានលក្ខខណ្ឌសមស្រប ដែលបានបំពេញការងាររយៈពេល៤ឆ្នាំ៖ អ្នកអាចធ្វើលិខិតអនុញ្ញាតឱ្យធ្វើការងាររបស់អ្នកជាថ្មីឡើងវិញ សម្រាប់រយៈពេលអតិបរមាចំនួន២ឆ្នាំ។ ទិដ្ឋាការប្រភេទ Non-LA របស់អ្នកក៏អាចពន្យារពេលបាន១ឆ្នាំទៀតផងដែរ ជាមួយនឹងការអនុញ្ញាតឱ្យពន្យារបន្តបាន ដរាបណាលិខិតអនុញ្ញាតឱ្យធ្វើការងារ និង លិខិតឆ្លងដែនរបស់អ្នកនៅតែមានសុពលភាព។
- ក្រុម២៖ ពលករមានលក្ខខណ្ឌសមស្រប ដែលបានប្តូរ ឬ កំពុងប្តូរនិយោជក៖ ប្រសិនបើលិខិតអនុញ្ញាតឱ្យធ្វើការងារ និង ស្នាក់នៅរបស់អ្នក លែងមានសុពលភាពដោយសារមានការផ្លាស់ប្តូរនយោជក អ្នកអាចធ្វើលិខិតអនុញ្ញាតឱ្យធ្វើការងារ និង ស្នាក់នៅរបស់អ្នកជាថ្មីបាន តាមរយៈដំណើរការដូចគ្នាទៅនឹងក្រុម១ដែរ ដោយមានកិច្ចគាំទ្រពីនយោជកថ្មី។
- ក្រុម៣៖ ពលករមានលក្ខខណ្ឌសមស្រប ដែលមានប័ណ្ណពណ៌ផ្កាឈូក៖ ប្រសិនបើអ្នកបានបំពេញដំណើរការផ្ទៀងផ្ទាត់សញ្ជាតិរួចរាល់ ប៉ុន្តែ មិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះមុនកាលបរិច្ឆេទកំណត់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ អ្នកអាចបន្តបំពេញដំណើរការ ដើម្បីពន្យារលិខិតអនុញ្ញាតឱ្យធ្វើការងាររបស់អ្នក ត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០។
- ក្រុម៤៖ ពលករមានលក្ខខណ្ឌសមស្រប ដែលឆ្លងដែនតាមរដូវកាល៖ ប្រសិនបើប័ណ្ណឆ្លងកាត់ព្រំដែនរបស់អ្នក បានផុតសុពលភាព ហើយអ្នកជាប់នៅក្នុងប្រទេសថៃដោយសារការឆ្លងរាតត្បាតជាសកលនៃជំងឺកូវីដ១៩ អ្នកអាចធ្វើប័ណ្ណឆ្លងកាត់ព្រំដែនរបស់អ្នកថ្មីបាន។ ការធ្វើប័ណ្ណថ្មីឡើងវិញម្តងៗមានសុពលភាពរយៈពេល៩០ថ្ងៃ រហូតដល់រយៈពេលអតិបរមា ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។
- ក្រុម៥៖ អ្នកនៅក្នុងបន្ទុករបស់ពលករទេសន្តរប្រវេសន៍ដែលមានលក្ខខណ្ឌសមស្រប (អ្នកនៅក្នុងបន្ទុករបស់ក្រុម១-៣) ប្រសិនបើអ្នកត្រូវបានចុះឈ្មោះជាអ្នកនៅក្នុងបន្ទុករបស់ពលករទេសន្តរប្រវេសន៍ណាម្នាក់ ហើយអ្នកទើបមានអាយុ១៨ឆ្នាំ ឬ កំពុងឈានចូលវ័យ១៨ឆ្នាំ អ្នកអាចដាក់ពាក្យសុំលិខិតអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការងារបាន។ ប្រសិនបើអ្នកមានអាយុ១៨ឆ្នាំ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ឬ មុនថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ហើយអ្នកមានបំណងចង់ធ្វើការងារនៅក្នុងប្រទេសថៃ អ្នកត្រូវមានលិខិតគាំទ្រពីអនាគតនិយោជក និង ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតឱ្យស្នាក់នៅ នឹងធ្វើការងារ ក្នុងរយៈពេល៦០ថ្ងៃ មុនថ្ងៃកំណើតគម្រប់អាយុ១៨ឆ្នាំរបស់អ្នក។

**ដំណើរការពន្យារលិខិតអនុញ្ញាត សម្រាប់ក្រុមពលករទេសន្តរប្រវេសន៍ និង អ្នកនៅក្នុងបន្ទុករបស់ពួកគេដែលមានលក្ខខណ្ឌសមស្រប៖**

- ដំណើរការពន្យារលិខិតអនុញ្ញាតសម្រាប់ ក្រុម១ (ពលករមានលក្ខខណ្ឌសមស្រប ដែលបានបំពេញការងាររយៈពេល៤ឆ្នាំ) ក្រុម២ (ពលករមានលក្ខខណ្ឌសមស្រប ដែលបានប្តូរ ឬ កំពុងប្តូរនយោជក) ក្រុម៣ (ពលករមានលក្ខខណ្ឌសមស្រប ដែលមានប័ណ្ណពណ៌ផ្កាឈូក) រួមមាន
  - ក) សុំលិខិតបញ្ជាក់វេជ្ជសាស្រ្តមួយច្បាប់ពីមន្ទីរពេទ្យណាមួយនៅក្នុងប្រទេសថៃដែលគេបានកំណត់ ដើម្បីបញ្ជាក់ថាអ្នកគ្មានជំងឺហង់សិន ជំងឺហើមដៃជើង ជំងឺស្វាយ ញៀនគ្រឿងញៀន ញៀនគ្រឿងស្រវឹង និង ជំងឺផ្លូវចិត្ត។
  - ខ) ទិញគម្រោងធានារ៉ាប់រងសុខភាពរយៈពេល២ឆ្នាំសម្រាប់ជនទេសន្តរប្រវេសន៍ (MHIS) ដែលអាចទិញបាននៅតាមមន្ទីរពេទ្យដែលត្រូវបានកំណត់ ប្រសិនបើអ្នកពុំមានសិទ្ធិទទួលបានបេឡារបបសន្តិសុខសង្គម (SSF) ឬ គម្រោងធានារ៉ាប់រងសុខភាពសម្រាប់ជនទេសន្តរប្រវេសន៍រយៈពេល៣ខែ ដែលអាចទិញបាននៅតាមមន្ទីរពេទ្យដែលត្រូវបានកំណត់ ប្រសិនបើអ្នកមានសិទ្ធិទទួលបានបេឡារបបសន្តិសុខសង្គម។
  - គ) សុំទិដ្ឋាការប្រភេទ Non-LA នៅតាមការិយាល័យអន្តោប្រវេសន៍ដែលមានមូលដ្ឋាននៅតាមខេត្ត/ក្រុងបាងកក។
  - ឃ) សុំប័ណ្ណអនុញ្ញាតឱ្យធ្វើការងារតាមប្រព័ន្ធអេឡិកត្រូនិក នៅឯការិយាល័យនៃនាយកដ្ឋានមុខរបរនិងការងារ  នៅតាមបណ្តាខេត្ត / ក្រុងបាងកកដែលអ្នកធ្វើការ។
- ដំណើរការពន្យារលិខិតអនុញ្ញាត ប្រសិនបើអ្នកមានលក្ខខណ្ឌសមស្រប ស្ថិតក្នុងក្រុមទី៤ (ពលករមានលក្ខខណ្ឌសមស្រប ដែលឆ្លងដែនតាមរដូវកាល) រួមមាន:
  - ជំហាន ក) និង ខ) គឺដូចគ្នាទៅនឹងចំណុចខាងលើសម្រាប់ក្រុម ១-៣
  - គ) ផ្តល់លិខិតបញ្ជាក់វេជ្ជសាស្ត្រ និង ប័ណ្ណធានារ៉ាប់រង ទៅការិយាល័យនៃនាយកដ្ឋាន មុខរបរនិងការងារនៅតាមបណ្តាខេត្ត /ក្រុងបាងកកដែលអ្នកធ្វើការ ដើម្បីទទួលបានប័ណ្ណឆ្លងកាត់ព្រំដែនថ្មី។
- ដំណើរការពន្យារលិខិតអនុញ្ញាត ប្រសិនបើអ្នកមានលក្ខខណ្ឌសមស្រប ស្ថិតក្នុងក្រុមទី៥ (អ្នកក្នុងបន្ទុករបស់ពលករទេសន្តរប្រវេសន៍ដែលទើបមានអាយុ១៨ឆ្នាំ ឬ បំរុងឈានដល់វ័យ១៨ឆ្នាំ) រួមមាន:
  - ជំហាន ក) និង ខ) គឺដូចគ្នាទៅនឹងចំណុចខាងលើសម្រាប់ក្រុម ១-៣
  - គ) ដាក់ ពាក្យសុំទៅការិយាល័យនៃនាយកដ្ឋានមុខរបរនិងការងារ នៅតាមបណ្តាខេត្ត /ក្រុងបាងកក ដែលអ្នកធ្វើការ
  - ង) សុំប័ណ្ណអនុញ្ញាតឱ្យធ្វើការងារតាមប្រព័ន្ធអេឡិកត្រូនិក នៅឯការិយាល័យនៃនាយកដ្ឋានមុខរបរនិងការងារ  នៅតាមបណ្តាខេត្ត / ក្រុងបាងកកដែលអ្នកធ្វើការ។

# តើអ្នកជាពលករទេសន្តរប្រវេសន៍ដែលការងាររបស់អ្នករងផលប៉ះពាល់ ពីការរាតត្បាតជាសកលនៃជំងឺកូវីដ១៩មែនទេ?

## តើអ្នកចង់បានព័ត៌មានបន្ថែម ឬ អ្នកកំពុងស្វែងរកសកម្មភាពដើម្បីធ្វើក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ដែរឬទេ?

សូមចូលទស្សនាគេហទំព័រ MitrThai.com សម្រាប់ព័ត៌មានបច្ចុប្បន្នភាព រួមទាំងវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍជំនាញ ដូចជា
ភាសាថៃ វិជ្ជាធ្វើម្ហូប
បដិសណ្ឋារកិច្ច សំណង់ និង
ជំនាញផ្នែកព័ត៌មានវិទ្យា។

## តើអ្នកមានជំងឺ និង ត្រូវការការថែទាំវេជ្ជសាស្ត្រមែនទេ?

សូមទៅមន្ទីរពេទ្យ ឬ មណ្ឌលសុខភាពដែលអ្នកត្រូវបានគេចុះឈ្មោះ។ ចូរបង្ហាញប័ណ្ណសន្តិសុខសង្គម ឬ ប័ណ្ណធានារ៉ាប់រងសុខភាពរបស់អ្នក។ ជនគ្រប់រូបដែលមានជំងឺដោយសារកូវីដ១៩ នឹងទទួលបានការព្យាបាលវេជ្ជសាស្ត្រជាបន្ទាន់ ដោយយោងទៅតាមសេចក្តីប្រកាសរបស់
ក្រសួងសុខភាពសាធារណៈ ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២០។

## តើអ្នកត្រូវការព័ត៌មាន និង ជំនួយបន្ថែមដែរឬទេ?

សម្រាប់ព័ត៌មានដែលគួរឱ្យជឿជាក់បាន និង មានបច្ចុប្បន្នភាព សូមសាកសួរនិយោជករបស់អ្នក ស្ថានទូត ឬ ស្ថានកុងស៊ុល **សមាគមកម្មករនិយោជិត និង អង្គការសង្គមស៊ីវិល ដូចជាក្រុមការងារ ទេសន្តរប្រវេសន៍** (contact@mwgthailand.org)

សូមហៅទៅទូរស័ព្ទលេខ ១៤២២ និង ចុចបន្តទៅកាន់លេខ ៨១ សម្រាប់ភាសាខ្មែរ លេខ ៨២ សម្រាប់ភាសាឡាវ និង លេខ ៨៣ សម្រាប់ភាសាភូមា ដែលនេះគឺជាលេខទូរស័ព្ទទាន់ហេតុការណ៍ ដំណើរការដោយនាយកដ្ឋានត្រួតពិនិត្យជំងឺ និង អង្គការសុខភាពពិភពលោក។ បណ្តាញទូរស័ព្ទទាន់ហេតុការណ៍នេះ មានប្រតិបត្តិការរៀងរាល់ថ្ងៃ (លើកលែងតែនៅថ្ងៃចុងសប្តាហ៍ និង ថ្ងៃឈប់សម្រាកបុណ្យជាតិ/អន្តរជាតិ) និងមានបម្រើពីម៉ោង៨:00ព្រឹក រហូតដល់ម៉ោង ៨:00យប់។ សូមកត់សម្គាល់ថាបណ្តាញទូរស័ព្ទទាន់ហេតុការណ៍នេះនឹងកំណត់យកថ្លៃសេវាពីអ្នកហៅទូរស័ព្ទចូល ក្នុងអត្រាតម្លៃទូរស័ព្ទក្នុងស្រុក ហើយបណ្តាញទូរស័ព្ទទាន់ហេតុការណ៍នេះអាចទាក់ទងបានចំពោះតែលេខទូរស័ព្ទថៃប៉ុណ្ណោះ

## ព័ត៌មានអំពីសេវាដែលមាននៅក្នុងប្រទេសថៃ

1. សេនានុព័ន្ធការងារ ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា
អាសយដ្ឋាន: 518/4 Pracha Uthit Road, Wang Thonglang, Bangkok 10310
ទូរស័ព្ទ: 02-957-5851-2

2. ក្រុមការងារទេសន្តរប្រវេសន៍
អ៊ីមែល: contact@mwgthailand.org

3. បណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងការងារ
ហៅទៅលេខ ១៥០៦ និង ចុចបន្តទៅលេខ ២ ដើម្បីនិយាយជាមួយការីទូរស័ព្ទជាភាសាខ្មែរ ឡាវ និង ភូមា

4. បណ្តាញទូរស័ព្ទទាន់ហេតការណ៍សម្រាប់ជំងឺកូវីដ១៩ នៃនាយកដ្ឋានត្រួតពិនិត្យជំងឺ និង អង្គការសុខភាពពិភពលោក
ហៅទៅលេខ ១៤២២ និង ចុចបន្តទៅកាន់លេខ ៨១ សម្រាប់ភាសាខ្មែរ លេខ ៨២ សម្រាប់ភាសាឡាវ និង លេខ ៨៣ សម្រាប់ភាសាភូមា។



IOM Thailand, 18th Floor, Rajanakarn Building, 3 South Sathorn Road, Bangkok 10120, Thailand
Tel: (+66) 2 343 9300 (Main Office) | Email: ThailandLHD@iom.int

# ១.មជ្ឈមណ្ឌលធនធានចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា

- មជ្ឈមណ្ឌលធនធានចំណាកស្រុក
ក្រុងប៉ោយប៉ែត
ខេត្តបន្ទាយមានជ័យ
អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)

ផ្សារមង្គល ឃុំប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
លោក ថោង វុធទេព
ទូរស័ព្ទ៖ ០៩២ ៥០១ ៧៦១
អ៊ីម៉ែល៖ vthoang@iom.int

*មជ្ឈមណ្ឌលធនធានចំណាកស្រុក
ខេត្តកំពង់ចាម
អង្គការភ្នំស្រី ដើម្បីអភិវឌ្ឍន៍ (PSOD)

ផ្ទះលេខ ១២៦ ផ្លូវមុន្នីវង្ស ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លោកស្រី ជាម ស្រីរ័ត្ន / លោក កេង សុខអាន
ទូរស័ព្ទ៖ ០៩៦ ២៦៨ ៣៨៣៣ / ០១៧ ៩៩៨ ៨១៨
អ៊ីម៉ែល៖ mrc@psodcambodia.org

*មជ្ឈមណ្ឌលធនធានចំណាកស្រុក
ខេត្តបាត់ដំបង
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

វិទ្យាស្ថានពហុបច្ចេកវិជ្ជា តេជោសែន ខេត្តបាត់ដំបង ក្រុងបាត់ដំបង
លោកស្រី ស៊ីប ស៊ីសុលី
ទូរស័ព្ទ៖ ០៩៧ ៣៦៩ ៧៧៧៩ / ០១៧ ៧១៤ ៤០៧
អ៊ីម៉ែល៖ sisoli020182@gmail.com
jc_battambang@nea.gov.kh

*មជ្ឈមណ្ឌលធនធានចំណាកស្រុក
ខេត្តកំពត
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

វិទ្យាស្ថានពហុបច្ចេកវិជ្ជា តេជោសែន ខេត្តកំពត
លោក ភឿក ចន្ធី
ទូរស័ព្ទ៖ ០១៦ ៥០ ៦៦ ៥៥ / ០៩២ ៩១៩១០៧
អ៊ីម៉ែល៖ phoeukchanthy7@gmail.com
jc_kampot@nea.gov.kh

*មជ្ឈមណ្ឌលធនធានចំណាកស្រុក
ខេត្តព្រៃវែង
សហភាពការងារកម្ពុជា

ផ្លូវលេខ ១១ ភូមិ ៤ ក្រុងព្រៃវែង
លោក ទេព សុភាព
ទូរស័ព្ទ៖ ០៩៧ ៧៧៦ ៥៨៥៨ / ០៧៨ ៣២៣ ៧៨៧
អ៊ីម៉ែល៖ sopheaptph88@gmail.com

*មជ្ឈមណ្ឌលធនធានចំណាកស្រុក
ខេត្តសៀមរាប
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

អាសយដ្ឋាន៖ វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប
សង្កាត់ស្លក្រាម ក្រុងសៀមរាប
ឈ្មោះ៖ លោក ស៊ាង សុខុន
នាយកមជ្ឈមណ្ឌលការងារខេត្តសៀមរាប
ទូរស័ព្ទ៖ ០៧៨ ៦៨២ ២៦៨ / ០៦៣ ២១០ ២៧៧
អ៊ីម៉ែល៖ sokhon_seang@yahoo.com jc_siemreap@nea.gov.kh

*មជ្ឈមណ្ឌលធនធានចំណាកស្រុក
ខេត្តកំពង់ធំ
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

អាសយដ្ឋាន៖ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ កំពង់ធំ
ភូមិអាចារ្យលាក់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ឈ្មោះ៖ លោក ខៀវ វឿន
ទូរស័ព្ទ៖ ០៧៧ ៤៥០ ៤៨៨ / ០១២ ៤៣៦ ៥៣៦
អ៊ីម៉ែល៖ voeunchem-khiev@yahoo.com jc_kampongthom@nea.gov.kh
វេបសាយ៖ www.nea.gov.kh

● មជ្ឈមណ្ឌលធនធានចំណាកស្រុកដាក់ឱ្យដំណើរការដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (អាយអូអឹម-IOM)"

* មជ្ឈមណ្ឌលធនធានចំណាកស្រុកទាំងនេះដាក់ឱ្យដំណើរការដោយអង្គការអន្តរជាតិខាងការងារ (ILO)"

# ២.មជ្ឈមណ្ឌលការងារ និងព័ត៌មានទំនាក់ទំនង ម៉ោងធ្វើការងារ៖ ចន្ទ-សុក្រ (៧:៣០-១១:៣០ព្រឹក & ១:៣០-៥:៣០ល្ងាច)

មជ្ឈមណ្ឌលការងារចល័ត
ទូរស័ព្ទ៖ ០៧០ ៣៥៦ ៦៥៥
អ៊ីម៉ែល៖ info@nea.gov.kh
www.nea.gov.kh
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

មជ្ឈមណ្ឌលការងារខេត្តកំពង់ធំ
វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ
ភូមិអាចារ្យលាក់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន
ទូរស័ព្ទ៖ ០៦២ ២១០ ២៧៧ / ០១៦ ៨៣៦ ៦៥៥
អ៊ីម៉ែល៖ jc_kampongthom@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តព្រៃវែង
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែង
ភូមិ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង
ទូរស័ព្ទ៖ ០៨១ ៧៨៦ ៦៥៥ / ០៤៣ ២១០ ២៧៧
អ៊ីម៉ែល៖ jc_preyveng@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តកំពត
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត
ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត
ទូរស័ព្ទ៖ ០៣៣ ២១០ ២៧៧ / ០១៦ ៥០៦ ៦៥៥
អ៊ីម៉ែល៖ jc_kampot@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តបន្ទាយមានជ័យ
វិទ្យាស្ថានពហុបច្ចេកទេស ខេត្តបន្ទាយមានជ័យ
ភូមិគាប សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ
ទូរស័ព្ទ៖ ០៥៤ ២១០ ២៧៧ / ០១៦ ៣២៦ ៦៥៥
អ៊ីម៉ែល៖ jc_banteaymeanchey@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង
ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង
ទូរស័ព្ទ៖ ០៤៤ ៧១៥ ២៧៧ / ០១៦ ៦៤៦ ៦៥៥
អ៊ីម៉ែល៖ jc_svayrieng@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តស្ទឹងត្រែង
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង
ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង
ទូរស័ព្ទ៖ ០៧៤ ២១២ ២៧៧ / ០១០ ៧៤៦ ៦៥៥
អ៊ីម៉ែល៖ jc_steungtreng@nea.gov.kh

មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ, ទូរស័ព្ទ៖ ០២៣ ៦៣៣ ៦០០២ / ០៧៧ ២៣២ ៣៧៨ / ០១៦ ៧៨៦ ៦៥៥
អ៊ីម៉ែល៖ jc_pp@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង
ផ្លូវលេខ១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ទូរស័ព្ទ៖ ០៥៣ ៧៣៣ ១១១ / ០១៦ ៩២៦ ៦៥៥
អ៊ីម៉ែល៖ jc_battambang@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តតាកែវ
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ
ភូមិ៣ សង្កាត់រកាក្នុង ក្រុងដូនកែវ
ទូរស័ព្ទ៖ ០៣២ ២១០ ២៧៧ / ០១៦ ៦៧៦ ៦៥៥
អ៊ីម៉ែល៖ jc_takeo@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តសៀមរាប
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប
សង្កាត់ស្លក្រាម ក្រុងសៀមរាប
ទូរស័ព្ទ៖ ០៦៣ ២១០ ២៧៧ / ០១៦ ៥៣៦ ៦៥៥
អ៊ីម៉ែល៖ jc_siemreap@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តព្រះសីហនុ
វិទ្យាស្ថានពហុបច្ចេកទេស ខេត្តព្រះសីហនុ
ភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ
ទូរស័ព្ទ៖ ០៣៤ ២១០ ២៧៧ / ០៨១ ៨៥៦ ៦៥៥
អ៊ីម៉ែល៖ jc_preahsihanouk@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តកំពង់ចាម
វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម
ផ្លូវលេខ៧ចាស់ ភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
ទូរស័ព្ទ៖ ០៤២ ២១០ ២៧៧ / ០១៦ ៦៥៦ ៦៥៥
អ៊ីម៉ែល៖ jc_kampongcham@nea.gov.kh

មជ្ឈមណ្ឌលការងារខេត្តពោធិ៍សាត់
វិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់
ភូមិចំការចេកខាងជើង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់
ទូរស័ព្ទ៖ ០៥២ ៧៤០ ២៧៧ / ០១០ ៧០៦ ៦៥៥
អ៊ីម៉ែល៖ jc_pursat@nea.gov.kh